ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# សេចក្តីជូនដំណឹង

## ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារ តាមក្រសួង ស្ថាប័ន

### មន្ត្រីកសិកម្មឃុំ និងមន្ត្រីនៃអគ្គនាយកដ្ឋានរតនាគារជាតិ

មណ្ឌលប្រឡង៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

សម័យប្រឡង៖ ថ្ងៃសៅរ៍ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤

### សិស្សមន្ត្រីក្រមការ និង សិស្សមន្ត្រីជាន់ខ្ពស់

មណ្ឌលប្រឡង៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

សម័យប្រឡង៖ ថ្ងៃអាទិត្យ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤

គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

ថ្ងៃ ពុធ ១៣កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែង** សូមជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យ សម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ នៃសាលាភូមិន្ទរដ្ឋបាល ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ត្រូវចូលរួមការប្រឡងលើវិញ្ញាសាសរសេរលើកទី១ ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

**ក-វិញ្ញាសាប្រឡង**

វិញ្ញាសាសរសេរលើកទី១ រួមមាន៖

១-ភាសាអង់គ្លេស ឬភាសាបារាំង "រយៈពេល ១ម៉ោង៣០នាទី"
(ពីម៉ោង ៨:០០នាទី ដល់ម៉ោង ៩:៣០នាទី) ១០០ពិន្ទុ មេគុណ១

២-សំណួរពហុចម្លើយពាក់ព័ន្ធនឹង(១)ចំណេះដឹងអំពីមុខងារសាធារណៈ ក្រមសីលធម៌វិជ្ជាជីវៈ គោលនយោបាយរបស់រាជរដ្ឋាភិបាល រដ្ឋបាលសាធារណៈ វប្បធម៌ទូទៅ ពលរដ្ឋវិទ្យា ប្រវត្តិសាស្ត្រ ភូមិសាស្ត្រកម្ពុជា អាស៊ាន និងសេដ្ឋកិច្ចកម្ពុជា(៥០ពិន្ទុ)និង(២)ចំណេះដឹងពាក់ព័ន្ធនឹងជំនាញ(៥០ពិន្ទុ) "រយៈពេល ២ម៉ោង"
(ពីម៉ោង ១០:០០នាទី ដល់ម៉ោង ១២:០០នាទី) ១០០ពិន្ទុ មេគុណ១។

**ខ-សម័យប្រឡង និងមណ្ឌលប្រឡង**

១-សម័យប្រឡង ថ្ងៃអាទិត្យ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤

២-មណ្ឌលប្រឡង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស្ថិតតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ)។

បញ្ជាក់៖

+បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងមុន ១ម៉ោង(ម៉ោង៧:០០នាទី) និងភ្ជាប់មកជាមួយនូវ៖

-សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

-ប៊ិកពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

+បេក្ខជនមិនត្រូវយកឯកសារផ្សេងៗ ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ, ទូរស័ព្ទ, នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។

+សម្លៀកបំពាក់សមរម្យ៖

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

ថ្ងៃ ពុធ ១៣ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែង** សូមជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យ សម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការ ជំនាន់ទី១១ នៃសាលាភូមិន្ទរដ្ឋបាល ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ត្រូវចូលរួមការប្រឡងលើវិញ្ញាសាសរសេរលើកទី១ ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

**ក-វិញ្ញាសាប្រឡង**

វិញ្ញាសាសរសេរលើកទី១៖ សំណួរពហុចម្លើយពាក់ព័ន្ធនឹងវប្បធម៌ទូទៅ ច្បាប់ រដ្ឋបាល នយោបាយ អាស៊ាន សេដ្ឋកិច្ច និងហិរញ្ញវត្ថុ "រយៈពេល១ម៉ោង៣០នាទី" ១០០ពិន្ទុ មេគុណ១។

**ខ-សម័យប្រឡង មណ្ឌលប្រឡង និងវេនប្រឡង៖**

១-សម័យប្រឡង ថ្ងៃអាទិត្យ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤

២-មណ្ឌលប្រឡង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស្ថិតតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ)។

៣-វេនប្រឡង៖

-**វេនទី១. ចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៥:៣០នាទី៖** សម្រាប់បេក្ខជនដែលជ្រើសរើសប៉ុស្តិ៍នៅរដ្ឋបាលក្រុង ស្រុក នៃខេត្តតាកែវ, ខេត្តត្បូងឃ្មុំ, ខេត្តបន្ទាយមានជ័យ, ខេត្តកំពង់ស្ពឺ, ខេត្តកំពង់ធំ, ខេត្តកំពត, ខេត្តកំពង់ឆ្នាំង, ខេត្តស្វាយរៀង, ខេត្តពោធិ៍សាត់, ខេត្តក្រចេះ, ខេត្តព្រះសីហនុ, ខេត្តកោះកុង, ខេត្តព្រះវិហារ, ខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តស្ទឹងត្រែង, ខេត្តឧត្តរមានជ័យ, ខេត្តប៉ៃលិន, ខេត្តកែប។

-**វេនទី២. ចាប់ពីម៉ោង ១៦:៣០នាទី ដល់ម៉ោង ១៨:០០នាទី៖** សម្រាប់បេក្ខជនដែលជ្រើសរើសប៉ុស្តិ៍នៅរដ្ឋបាលខណ្ឌ ក្រុង ស្រុក នៃរាជធានីភ្នំពេញ, ខេត្តកណ្តាល, ខេត្តកំពង់ចាម, ខេត្តបាត់ដំបង, ខេត្តព្រៃវែង, ខេត្តសៀមរាប។

បញ្ជាក់៖

+បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងមុន ១ម៉ោង(មុនចាប់ផ្តើមប្រឡងវេននីមួយៗ) និងភ្ជាប់មកជាមួយនូវ៖

-សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬធាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

-ប៊ិកពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

+បេក្ខជនមិនត្រូវយកឯកសារផ្សេងៗ ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ, ទូរស័ព្ទ, នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។

+សម្លៀកបំពាក់សមរម្យ៖

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : មស.

ថ្ងៃ ពុធ ១៣ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

# សេចក្ដីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែង** សូមជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យ សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ត្រូវចូលរួមការប្រឡង ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

**ក-វិញ្ញាសាប្រឡង**

១-វិញ្ញាសាសរសេរ៖ ជំនាញ/ឯកទេសពាក់ព័ន្ធកសិកម្ម "រយៈពេល២ម៉ោង"
(ពីម៉ោង ១២:០០នាទី ដល់ម៉ោង១៤:០០នាទី) ១០០ពិន្ទុ មេគុណ២

២-វិញ្ញាសាពហុចម្លើយ៖ ភាសាអង់គ្លេសកម្រិតមូលដ្ឋានពាក់ព័ន្ធកសិកម្ម "រយៈពេល១ម៉ោង"
(ពីម៉ោង១៥:០០នាទី ដល់ម៉ោង ១៦:០០នាទី) ៥០ពិន្ទុ មេគុណ១

៣-វិញ្ញាសាពហុចម្លើយ៖(១)ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ ក្រមសីលធម៌វិជ្ជាជីវៈ គោលនយោបាយរបស់រាជរដ្ឋាភិបាល រដ្ឋបាលសាធារណៈ វប្បធម៌ទូទៅ ពលរដ្ឋវិទ្យា ប្រវត្តិសាស្ត្រ ភូមិសាស្ត្រកម្ពុជា អាស៊ាន និងសេដ្ឋកិច្ចកម្ពុជា(៥០ពិន្ទុ)និង(២)ចំណេះដឹងពាក់ព័ន្ធនឹងជំនាញ/ឯកទេសកសិកម្ម(៥០ពិន្ទុ)"រយៈពេល១ម៉ោង"
(ពីម៉ោង ១៧:០០នាទីដល់ម៉ោង១៨:០០នាទី) ១០០ពិន្ទុ មេគុណ១។

**ខ-សម័យប្រឡង និងមណ្ឌលប្រឡង**

១-សម័យប្រឡង ថ្ងៃសៅរ៍ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤

២-មណ្ឌលប្រឡង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស្ថិតតាមបណ្ដោយមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ)។

បញ្ជាក់៖

+បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងមុន ១ម៉ោង(ម៉ោង១១:០០នាទី) និងភ្ជាប់មកជាមួយនូវ៖

-សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

-ប៊ិកពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

+បេក្ខជនមិនត្រូវយកឯកសារផ្សេងៗ ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ, ទូរស័ព្ទ, នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។

+សម្លៀកបំពាក់សមរម្យ៖

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

ថ្ងៃ ពុធ ១៣ កើត ខែកត្ដិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

# សេចក្ដីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែង** សូមជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យ សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ត្រូវចូលរួមការប្រឡង ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

**ក-វិញ្ញាសាប្រឡង**

១-វិញ្ញាសាសរសេរ៖ ជំនាញ/ឯកទេស "រយៈពេល២ម៉ោង"
(ពីម៉ោង ១២:០០នាទី ដល់ម៉ោង១៤:០០នាទី) ១០០ពិន្ទុ មេគុណ២

២-វិញ្ញាសាពហុចម្លើយ៖ ភាសាអង់គ្លេស "រយៈពេល១ម៉ោង"
(ពីម៉ោង១៥:០០នាទី ដល់ម៉ោង ១៦:០០នាទី) ៥០ពិន្ទុ មេគុណ១

៣-វិញ្ញាសាពហុចម្លើយ៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ ក្រមសីលធម៌វិជ្ជាជីវៈ គោលនយោបាយរបស់រាជរដ្ឋាភិបាល រដ្ឋបាលសាធារណៈ វប្បធម៌ទូទៅ ពលរដ្ឋវិទ្យា ប្រវត្តិសាស្ត្រ ភូមិសាស្ត្រកម្ពុជា អាស៊ាន និងសេដ្ឋកិច្ចកម្ពុជា(៥០ពិន្ទុ)និង២-ចំណេះដឹងពាក់ព័ន្ធនឹងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៥០ពិន្ទុ) "រយៈពេល១ម៉ោង"
(ពីម៉ោង ១៧:០០នាទីដល់ម៉ោង១៨:០០នាទី) ១០០ពិន្ទុ មេគុណ១។

**ខ-សម័យប្រឡង និងមណ្ឌលប្រឡង**

១-សម័យប្រឡង ថ្ងៃសៅរ៍ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤

២-មណ្ឌលប្រឡង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស្ថិតតាមបណ្ដោយមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ)។

បញ្ជាក់៖

+បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងមុន ១ម៉ោង(ម៉ោង១១:០០នាទី) និងភ្ជាប់មកជាមួយនូវ៖
-សលាកបត្រងកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬធាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។
-ប៊ិកពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

+បេក្ខជនមិនត្រូវយកឯកសារផ្សេងៗ ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ, ទូរស័ព្ទ, នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។

+សម្លៀកបំពាក់សមរម្យ៖
• សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ក្រោមជង្គង់ និងអាវពណ៌ស
• សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**